



# JST ជាអង្គការដែលឧបត្ថម្ភគាំទ្រដល់ ប្រជាជន ដែលកំពុងរស់នៅជាមួយ សម្បត្តិបេតិកភណ្ឌ

ទំនាក់ទំនងរវាងអ្នកភូមិទាំងអស់ជាមួយនឹងកម្មកររស់នៅភូមិនគរក្រៅ ដែលមកធ្វើការនៅការដ្ឋានជួសជុលប្រាសាទ រួមជាមួយអ្នកឯកទេសជនជាតិជប៉ុនដែលត្រូវបានគេបញ្ជូនមកធ្វើការងារជួសជុលប្រាសាទក្នុងតំបន់អង្គរ បានចាប់ផ្តើមកកើតមានឡើងនៅឆ្នាំ១៩៩៤មក។ នៅឆ្នាំ២០០៥ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលមានឈ្មោះថា JST បានចាប់កំណើតលេចជារូបរាងឡើង។ ពិតជាមានភាពល្អប្រសើរខ្លាំងណាស់ ប្រសិនបើអង្គការ JST អាចស្ថិតនៅក្នុងឋានៈជាកន្លែងប្រមូលផ្តុំ សម្រាប់មនុស្សម្នាទាំងឡាយ រួមមានដូចជាភ្ញៀវទេសចរបរទេសដែលមកទស្សនាប្រាសាទ អ្នកភូមិដែលធ្វើការនៅតាមប្រាសាទ រួមទាំងភ្ញៀវបរទេសដែលជាប់ចិត្តស្រឡាញ់បរិយាកាស និងប្រវិត្តសាស្ត្រកម្ពុជា មកជួបជុំគ្នា ដើម្បីស្វែងយល់ និងសិក្សាអំពីប្រាង្គប្រាសាទបុរាណ។

### កិច្ចថែរក្សាការពារប្រាសាទ

- ការអប់រំស្តីអំពីការជួសជុលប្រាសាទបុរាណ
- កម្មវិធីសុខុមាលភាពសម្រាប់អ្នកបច្ចេកទេស
- ការបណ្តុះបណ្តាលធនធានមនុស្ស ។ល។

រក្សាកេរមរតកវប្បធម៌ និង ប្រាង្គប្រាសាទបុរាណ ហើយបន្សល់ទៅកូនចៅជំនាន់ក្រោយៗ។

បង្កើតបរិយាកាសការងារប្រកបដោយទំនុកចិត្តដល់អ្នកភូមិដែលកំពុងធ្វើការតាមប្រាសាទ។

JST + ទេសចរបរទេស

### កិច្ចឧបត្ថម្ភកុមារ

- ការថែទាំសុខុមាលភាព
- ការផ្គត់ផ្គង់សម្ភារៈសិក្សា ។ល។

### កិច្ចអភិវឌ្ឍន៍ក្នុងតំបន់

- ការអប់រំស្តីអំពីបរិស្ថាន
- សកម្មភាពដាំកូនឈើ ។ល។

ជម្រុញឲ្យកុមារមានកម្លាំងចិត្តសិក្សា និងមានសុខភាពល្អ ដើម្បីក្លាយជាកម្លាំងជម្រុញការអភិវឌ្ឍន៍ក្នុងតំបន់





## ផែនទីភូមិនគរក្រៅ




## អាស័យដ្ឋានទំនាក់ទំនងអង្គការ JST

JST HP : http://www.jst-cambodia.net
Email : info@jst-cambodia.net

**ទីស្នាក់ការកណ្តាលនៃអង្គការ JST នៅកម្ពុជា** (JASA/UNESCO OFFICE)
អាស័យដ្ឋាន : #056,ក្រុមទី6, ភូមិត្រពាំងសេះ, ឃុំគោកចក, ស្រុកសៀមរាប
ប្រធាន : ជា ណុល
អ្នកទទួលបន្ទុក : Yoko Koide / Mai Yoshikawa
TEL: 012-627277 / FAX : 063-760-249

**ទីស្នាក់ការកណ្តាលនៃអង្គការ JST នៅជប៉ុន**
អាស័យដ្ឋាន : 3-4-1 Okubo, Shinjuku-ku, Tokyo, 169-8555, 55S-9-08
( ទីពិសោធន៍ NAKAGAWA ឯកទេសប្រវត្តិស្ថាបត្យកម្ម នៃមហាវិទ្យាល័យវិទ្យាសាស្ត្រនិងវិស្វកម្ម នៃសាកលវិទ្យាល័យ WASEDA )

■ **ការចូលរួមជាអ្នកស្ម័គ្រចិត្ត ឬជានិស្សិតចុះស្រាវជ្រាវ**
អង្គការ JST កំពុងទទួលស្វាគមន៍ចំពោះនិស្សិតចុះស្រាវជ្រាវ សម្រាប់រយៈពេលខ្លី និងរយៈពេលវែង។ ចំពោះអ្នកមានចំណាប់អារម្មណ៍សូមចូលទៅក្នុង គេហទំព័រ !

× ក្រុមការងារនៃអង្គការ JST

អ្នកគាំទ្រពិសេស : ក្រុមរដ្ឋាភិបាលជប៉ុន-អាជ្ញាធរអប្សរា ដើម្បីថែរក្សាប្រាសាទអង្គរ (JASA)
National Federation of UNESCO Associations in JAPAN

Angkor Yamanami Fund
NPO OASIS International
KINAN UNESCO Association
KOTA Circuit YRP Kiriyama
International Development Center of Japan(IDCJ)
Tools for Self Reliance
Seishin Joshi Gakuin
KDDI Co., Ltd.
TOYAMA Loins Club
Tanabe International Exchange Society(TIES)
Toki International Exchange Society
Ichinomiya Tyuo Rotary Club
Shiogama Rotary Club
Tokyo Shimbashi Rotary Club
Tokyo Rainbow Rotary Club
Tokoname The Rotary Club
Together To the Future(TTF)
MITA & Co., Ltd.
HAJIME JUKU
Recycling Organization
TAIWA SEIKI Co., Ltd.
ROTARACT (Aichi)
Cafe Moi Moi

# Joint Support Team for Angkor Preservation and Community Development





# JST

2013

# ការការពារប្រាសាទ

ដើម្បីឲ្យប្រជាជននៅក្នុងតំបន់បន្តការជួសជុលប្រាសាទដោយមានទំនុកចិត្តនិងដើម្បីឲ្យពន្លកត្រួយដែលយើងបានដាំថែរក្សាមកនោះអាចតភ្ជាប់ទៅជំនាន់ក្រោយបានដោយមានស្ថេរភាពនោះ អង្គការJSTនិងJASAបានសហប្រតិបត្តិការគ្នាដោយធ្វើការជ្រោមជ្រែងសកម្មភាពជួសជុលប្រាសាទនិងបុគ្គលិកជំនាញ។

## ការចាប់ផ្តើមសកម្មភាពជួសជុលរូបសំណាកនាគនិងតោនៅប្រាសាទបាយ័ន

រយៈជាង20ឆ្នាំមកនេះនៅក្នុងសកម្មភាពដ៏រីកចំរើនបំផុតមួយដែល JASAបានអភិវឌ្ឍន៍ ធនធានមនុស្សហើយក្នុងនោះJSTក៏មានទិសដៅឲ្យមានការផ្ទេរបច្ចេកវិទ្យាពីជនជាតិកម្ពុជាទៅជនជាតិកម្ពុជា ដូច្នេះនៅឆ្នាំ2012ក៏មានជាគំនិតផ្តួចផ្តើមថ្មីមួយដោយបានចាប់ផ្តើមសកម្មភាពជួសជុលរូបសំណាកនាគនិងតោនៅប្រាសាទបាយ័ន។ ដើម្បីសកម្មភាពការងារថ្មីមួយនេះអ្នកជំនាញជើងថ្មីដែលមកពីភូមិជុំវិញតំបន់អង្គរធំសព្វថ្ងៃកំពុងរីកចំរើនឥតឈប់ឈរដោយទទួលជំនាញជួសជុលប្រាសាទនិងជួសជុលថ្មពីអង្គការ JASA។



※ ការងារនេះធ្វើឡើងរួមគ្នាដោយស្ថិតនៅក្រោមកិច្ចសហប្រតិបត្តិការរវាងក្រុមបច្ចេកទេសJASA និងសហព័ន្ធនៃសមាគមន៍ជប៉ុនយូណេស្កូ។

## ដំណើរចុះកម្មសិក្សាសង្គមសម្រាប់កុមារនៅកម្ពុជា



សៀមរាបគឺជាខេត្តមួយដែលតំណាងឲ្យប្រទេសកម្ពុជាដែលមានក្រុមបេតិកភណ្ឌវប្បធម៌ប៉ុន្តែឃើញថាស្ថានភាពសព្វថ្ងៃនៃការអប់រំរបស់កុមារជាមួយនឹងបេតិកភណ្ឌវប្បធម៌មិនទាន់មានភាពទាក់ទងគ្នានៅឡើយទេ។ នៅក្នុងនោះដោយសារអង្គការJSTជាអង្គការNGOដែលរួមសហប្រតិបត្តិការជាមួយក្រុមជួសជុលប្រាសាទបុរាណដូច្នេះនៅឆ្នាំ2009ក៏បានផ្តល់ឱកាសដល់ក្មេងៗកម្ពុជាដោយបានបង្កើតកម្មវិធីដំណើរចុះកម្មសិក្សាសង្គមសម្រាប់ក្មេងៗកម្ពុជា។ ដើម្បីឲ្យប្រាសាទបុរាណរបស់យើងអាចដើរទន្ទឹមទៅជាមួយអនាគតខាងមុខដ៏យូរអង្វែងបាន យើងកំពុងតែស្វែងរកជំនួយពីអស់លោកអ្នកដែលអាចជួយជ្រោមជ្រែងដល់កម្មវិធីដំណើរចុះកម្មសិក្សាសង្គមរបស់យើងផងដែរ។

## ការផ្សព្វផ្សាយសកម្មភាពជួសជុលប្រាសាទ

ដើម្បីឲ្យកុមារនៅកម្ពុជាបានស្គាល់ពីភាពគួរឲ្យចាប់អារម្មណ៍នៃប្រាសាទបុរាណខ្មែរនិងសារៈសំខាន់នៃការជួសជុលប្រាសាទផងដែរនោះ JSTបាននឹងកំពុងបង្កើតសៀវភៅរូបភាពមួយ អំពីការជួសជុលប្រាសាទ។ ម៉្យាងទៀតប្រាក់ចំនេញដែលបានមកពីការបង្កើតដំណើរកំសាន្តទស្សនកិច្ចនៅការដ្ឋានជួសជុលក៏ដូចជាទស្សនកិច្ចនៅភូមិនគរក្រៅដែលមានក្នុងការរៀបចំរបស់JSTនោះគឺមួយផ្នែក ផ្តល់ទៅឲ្យការអប់រំសម្រាប់កុមារនិងមួយផ្នែកទៀតផ្តល់សំរាប់សុខុមាលភាពរបស់កម្មករ ជួសជុលប្រាសាទផងដែរ។



សៀវភៅរូបភាពជួសជុល កំពុងនឹងជិតបញ្ចប់

ក្នុងឆ្នាំ2012មានភ្ញៀវបរទេសលើសពី2000នាក់ដែលបានមកចូលមក JSTក្នុងនោះភ្ញៀវជនជាតិជប៉ុនមានចំនួនច្រើនជាងគេ។ ការមានចំណាប់អារម្មណ៍ និងការមកចូលទស្សនា JST គឺជាកំលាំងជួយដល់តំបន់ និងប្រាសាទបុរាណយើង។

# ការដើរឆ្ពោះទៅមុខស្របជាមួយស្ថានភាពក្នុងតំបន់

យើងមានគោលបំណងចំពោះប្រទេសកម្ពុជាទៅថ្ងៃអនាគតគឺប្រជាជនកម្ពុជាខ្លួនឯងផ្ទាល់ជាអ្នកកសាងអនាគតប្រទេសដោយខ្លួនឯង ដូច្នេះJSTផ្តោតការសង្កត់ធ្ងន់ទៅលើការបណ្តុះបណ្តាល កុមារ និងយុវជនអោយក្លាយទៅជាធនធានមនុស្សដូចជាគ្រូបង្រៀន យុវជនគំរូ ជាដើមទៅថ្ងៃអនាគត។

## យើងសាងសង់សាលាអនុវិទ្យាល័យទាំងអស់គ្នា!

នៅតំបន់ជនបទ កុមារជាច្រើនសឹងតែមិនមានឱកាសសិក្សាអំពី លំហាត់ប្រាណ សិល្បៈ ភាសាបរទេស ជាដើម។ ដូចនេះហើយសាលាយ៉ាម៉ាណាមិ(YAMANAMI) ដែលឋិតនៅក្នុងមជ្ឈមណ្ឌលទំនាក់ទំនងភូមិនគរក្រៅ បានបើកនូវថ្នាក់សិក្សាដូចជា គូររូបថ្នាក់ភាសាអង់គ្លេស និងភាសាជប៉ុន។ល។ ម៉្យាងទៀត ក្នុងគោលបំណងជំរុញការអប់រំដល់កុមារ អង្គការJST តែងតែចែកជូននូវវត្ថុជាច្រើនដែលជាអំណោយពីសប្បុរសជនជប៉ុនដូចជា កាបូបស្ពាយ សំភារៈសិក្សាឯកសណ្ឋាន ជាដើមដល់សិស្សានុសិស្សក្នុងតំបន់នោះ។ ម៉្យាងទៀតដោយសារគ្មានអនុវិទ្យាល័យនៅជិតភូមិទើបពួកគេមិនដែលគិតដល់ការបន្តការសិក្សា និងគោលបំណងទៅថ្ងៃអនាគតរបស់ពួកគេឡើយ។ អ្នកភូមិទាំងអស់បានសំណូមពរដូចៗគ្នាថា«ខ្ញុំត្រូវការសាលាអនុវិទ្យាល័យ!» ទើបអង្គការJSTបានចាប់ផ្តើមសាងសង់អនុវិទ្យាល័យដោយបានផ្តោតទៅលើសិស្សានុសិស្សដែលនឹងបញ្ចប់ការសិក្សានៅបឋមសិក្សាទាំង5ដែលមានទីតាំងឋិតនៅតំបន់ភាគខាងលិចរាជធានីអង្គរធំ។ នៅខែតុលាឆ្នាំ2013នេះគ្រោងនឹងបញ្ចប់ការសាងសង់បន្ទប់សិក្សាដំបូង ហើយក្លាយទៅជាសាលាអនុវិទ្យាល័យរដ្ឋដំបូងគេក្នុងតំបន់នោះ។ JSTក៏ចូលរួមជួយជ្រោមជ្រែងផងដែរដើម្បីឆ្ពោះទៅរកការអប់រំដែលមានលក្ខណៈស្របទៅតាមតំបន់ដោយមានបន្ថែមមុខវិជ្ជាសិក្សាផ្សេងទៀតដូចជាសិល្បៈ កសិកម្ម ភាសាបរទេស ការជួសជុលប្រាសាទជាដើម។

## ការគាំទ្រស្មារតីកុមារនៅក្នុងភូមិ

ក្នុងឆ្នាំ2012គឺចូលដល់ឆ្នាំទី3ដែលយើងបានបង្កើតកម្មវិធីអាហារថ្ងៃត្រង់នៅសាលា។ ជាធម្មតាក្មេងៗនៅក្នុងភូមិក្រមបានបរិភោគអាហារដែលមានជីវជាតិបំប៉នដល់សុខភាពណាស់ ដូច្នេះJSTបានបង្កើតកម្មវិធីដាំបបរជីវជាតិដែលមានគ្រឿងផ្សំចម្រុះដូចជាសាច់ជាមួយបន្លែដែលធ្វើឲ្យ ក្មេងៗក្នុងភូមិត្រេកអរជាខ្លាំងដោយទទួលបាននូវការញ៉ាំបបរជីវជាតិថែមដោយសេរីនេះ។



ការផ្តត់ផ្គង់ជំនួយពីប្រទេសជប៉ុន សកម្មភាពដ៏ធំនៅក្នុងភូមិ!



ស្មារតីកុមារគឺជាស្មារតីជំនួយក្នុងភូមិ

ដំណើរកំសាន្តគួបសកម្មភាពជួសជុលប្រាសាទ!
លោកអ្នកអាចអញ្ជើញចូលទស្សនាការដ្ឋានជួសជុលកន្លះថ្ងៃក៏បាន!
→ គេហទំព័រ JST : http://www.jst-cambodia.net

## ការសំរេចជោគជ័យនៃគម្រោងអប់រំបរិស្ថាននិងអនាម័យ

យើងបានបញ្ចប់គម្រោងសកម្មភាពលើកកម្ពស់ការដាំកូនឈើនិងការអប់រំបរិស្ថានទៅអនាគតនៅក្នុងសាលាបឋមសិក្សាក្នុងតំបន់ដែលដឹកនាំដោយក្រុមយុវជនភូមិនគរក្រៅ ដែលបានអនុវត្តន៍សកម្មភាពនេះនៅតាមសាលាបឋមសិក្សាទាំង16នៅក្នុងតំបន់អស់រយៈពេល3ឆ្នាំមកហើយ។ សាលាបឋមសិក្សា ដែលស្ថិតនៅតាមជនបទមកដល់ឥឡូវនេះគឺមិនទាន់មានសកម្មភាព ការធ្វើអនាម័យ ការថែរក្សាបរិស្ថានព្រៃឈើ ក៏ដូចជាការដោះស្រាយបញ្ហាសំរាមនៅឡើយទេប៉ុន្តែដោយក្រុមយុវជនបានអនុវត្តន៍សកម្មភាពទាំងនេះនៅតាមសាលាបឋមសិក្សានីមួយៗអស់រយៈ ពេល3ឆ្នាំមកឃើញថាមានការប្រសើរឡើងគួរឲ្យកត់សម្គាល់។ ម៉្យាងទៀតយើងឃើញមានសកម្មភាពដ៏អស្ចារ្យមួយទៀតរបស់ក្រុមយុវជន។ បច្ចុប្បន្ននេះពួកគេកំពុងបង្កើតសកម្មភាពចិញ្ចឹមត្រីអណ្តែងនិងដាំបន្លែដោយធ្វើទំនាក់ទំនងផ្លាស់ប្តូរបទពិសោធន៍ជាមួយក្រុមនិស្សិតបរទេសដែលមកStudy Tour ដើម្បីគាំទ្រធនធានមនុស្សសម្រាប់អនាគតភូមិ និងដើម្បីជាចំណងទំនាក់ទំនងរវាងភូមិទៅពិភពខាងក្រៅ។



សកម្មភាពនៃក្រុមយុវជននេះធ្វើឲ្យមានការលើកកម្ពស់ដល់តម្លៃប្រទេសក៏ដូចជាភូមិទាំងមូលផងដែរ។ យើងសង្ឃឹមថាសកម្មភាពរបស់ពួកគេនឹងកាន់តែរីកចម្រើនទូលំទូលាយជាងនេះ។